**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១០៣/០០៣/២០០៦

ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**

លេខ : ០៧៥/០០២/២០០៦ កបធ.ច

ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/១០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការយល់ព្រម និង ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងពីការទទួលស្គាល់ និង ការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស
- បានឃើញសំណើលេខ ៣០០ រស ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានយល់ព្រមឱ្យរដ្ឋសភាបន្តនីតិវិធីតាមរយៈលិខិតលេខ ០១៧/០៣០៦/ពស/នវ ចុះថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០០៦ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលសំណើនេះ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ វេលាម៉ោង ១០:៤០ នាទី ព្រឹក ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់របាយការណ៍បំភ្លឺរបស់តំណាងក្រសួងពាណិជ្ជកម្ម**

**ក្រោយពីបានពិភាក្សាក្នុងសម្ងាត់តាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ មុននឹងច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់នេះ
- យល់ឃើញថា មាត្រា ៥ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបកស្រាយថា តុលាការអាចធ្វើអន្តរាគមន៍ បានក្នុងករណីដែលភាគីស្នើសុំ ហើយមិនកម្រិតអំណាចរបស់តុលាការឡើយ
- យល់ឃើញថា មាត្រា ៤២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលបានប្រគល់សិទ្ធិឱ្យសាលាឧទ្ធរណ៍សម្រេច លើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបានតែក្នុងករណីដែលតុលាការពាណិជ្ជកម្ម មិនទាន់បានបង្កើត
- យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្រៅពីមាត្រា ៥ និងមាត្រា ៤២ ដែលបានកត់ សម្គាល់ខាងលើ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.** ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានយល់ព្រមអោយរដ្ឋសភាបន្តនីតិវិធីតាមរយៈលិខិត លេខ ០១៧/០៣០៦/ពស/នវ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែល មានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន